ព្រះរាជាណាចក្រកម្ពុជា បានថតចម្លងត្រឹមត្រូវអេញពី

ជាតិ សាសនា ព្រះមហាក្សត្រ ច្បាប់ដើមដោយម៉ាស៊ីនហ្វូតូកូពី

សៀមរាប, ថ្ងៃទី៣០...ខែ...ឆ្នាំ២០១៧

ក្រឡាបញ្ជី

សាលាដំបូង ខេត្តសៀមរាប

សំណុំរឿងព្រហ្មទណ្ឌលេខ : ៨៦៣
ចុះថ្ងៃទី០៦ ខែ សីហា ឆ្នាំ២០១៦
ជំនុំជម្រះលេខ : ២១៨
ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៧
សាលក្រមព្រហ្មទណ្ឌលេខ: ២៥ "ខ"
ចុះថ្ងៃទី២៨ ខែមេសាឆ្នាំ ២០១៧

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្ត សៀមរាប

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងខេត្ត សៀមរាប

សាលសវនាការលេខ : ០២

កាលបរិច្ឆេទបើកសវនាការ : ថ្ងៃទី ២៨ ខែមេសា ឆ្នាំ ២០១៧ វេលា ល្ងាច [redacted]

កាលបរិច្ឆេទប្រកាសសាលក្រម: ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០១៧ វេលា ល្ងាច

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

កញ្ញា [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី

**មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ**

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឈ្មោះ [redacted] ធីតា ហៅ អាកា

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឈ្មោះ [redacted] ធីតា ហៅ អាកា

លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

ឈ្មោះ [redacted] ប៊ុនថន

*ដើម្បីជំនុំជម្រះ*សំណុំរឿងព្រហ្មទណ្ឌលេខ : ៨៦៣ ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០១៦ ដែលមាន:

**ជនជាប់ចោទ**

១.ឈ្មោះ [redacted] ប៊ុនថន ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ១០.០៥.១៩៩០ ជនជាតិខ្មែរ ។ កើតនៅភូមិ សំពងជ័យ ឃុំ សំពងជ័យ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ អាសយដ្ឋានបច្ចុប្បន្នមុនពេលឃុំខ្លួននៅភូមិតា

Scanned by CamScanner

ភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មុខរបរជាងឡានកាន់សាសនាព្រះពុទ្ធ លីវ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន: គ្មាន។

ជាប់ចោទពីបទ : "រក្សាទុកនិងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន"ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌទី ១,៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ឈ្មោះ [redacted] ធីតា ភេទស្រី អាយុ១៨ឆ្នាំ ជនជាតិខ្មែរ។ កើតនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប។ អាសយដ្ឋានបច្ចុប្បន្នមុនពេលឃុំខ្លួននៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប មុខរបរជាងអ៊ុតសក់ កាន់សាសនាព្រះពុទ្ធ នៅលីវ ឪពុកឈ្មោះ កែ (រ) ម្តាយឈ្មោះ [redacted] (រ) ទោសពីមុន: គ្មាន។

ជាប់ចោទពីបទ :" សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន " ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ កថាខណ្ឌទី ៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

-បានឃើញ : ដីកាសន្និដ្ឋានស្ថាពរលេខ: ៧៦ ចុះថ្ងៃទី ១៨ -០១ -២០១៧

-បានឃើញ : ដីកាដំណោះស្រាយបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៧៦ ចុះថ្ងៃទី ២៦-០១- ២០១៧

-បានឃើញ : ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ : ៣១០ ចុះថ្ងៃទី ២៣-០៣- ២០១៧

-បានឃើញ : ដីកាផ្តល់ដំណឹងកាលបរិច្ឆេទសវនាការ ដែលធ្វើឡើងដោយអនុលោមតាមមាត្រា ២៩២ និងមាត្រាបន្តបន្ទាប់នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

## ដំណើររឿងហេតុកើតឡើងមានដូចតទៅ

កាលពីថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៦ សមត្ថកិច្ចចម្រុះធ្វើការត្រួតពិនិត្យរដ្ឋបាលតាមបន្ទប់ជួលនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប រកឃើញថ្នាំញៀនមួយកញ្ចប់តូចទម្ងន់ ០,១ (សូន្យក្បៀសមួយ)ក្រាម និងជញ្ជីងថ្លឹង ព្រមទាំងសម្ភារៈវេចខ្ចប់មួយចំនួនក្នុងបន្ទប់ជួលរបស់ឈ្មោះ [redacted] ប៊ុនថន និងឈ្មោះ [redacted] ធីតា ជាសង្សាររបស់ឈ្មោះ [redacted] ប៊ុនថន។ តាមចម្លើយសារភាពរបស់ឈ្មោះ [redacted] នថន ថាខ្លួនទិញថ្នាំញៀន ០១កញ្ចប់ ពីជនម្នាក់មិនស្គាល់ឈ្មោះយកមកសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងបានរំលែកបន្តិចបន្តួចទុកលក់ចែកឱ្យមិត្តភក្តិផងដែរ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថន បានឆ្លើយថា : ខ្លួនធ្លាប់បានជក់ថ្នាំញៀនជាយូរខែមកហើយ ព្រមទាំងរំលែកលក់ឱ្យគេខ្លះៗ ដើម្បីយកកម្រៃទិញជក់បន្តទៀត ។ នៅថ្ងៃទី ០៤ ខែសីហា ឆ្នាំ២០១៦ ខ្លួនបានទិញថ្នាំញៀនពីគេមួយកញ្ចប់តម្លៃ ៣០ ដុល្លារ យកមកទុកជក់ផ្ទាល់ខ្លួន និងបានរំលែកជាកញ្ចប់តូចៗ ចំនួន ០៥កញ្ចប់ លក់ឱ្យគេបានប្រាក់ ៤០,០០០ រៀល ក្នុងមួយកញ្ចប់ នៅថ្ងៃដដែលនោះខ្លួនបានជក់ថ្នាំញៀនជាមួយសង្សារ នៅក្នុងបន្ទប់ជួល ។ ព្រឹកឡើងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ សមត្ថកិច្ចបានចូលមកឆែកឆេរបន្ទប់របស់ខ្លួនបានឃើញខ្លួន និងសង្សាររបស់ខ្លួនកំពុងជក់ថ្នាំសមត្ថកិច្ចក៏បានចាប់ឃាត់ខ្លួន និងសង្សារខ្លួននៅពេលនោះតែម្តង ។ ខ្លួនសន្យាឈប់ប្រព្រឹត្តអំពើនេះតទៅទៀតហើយខ្លួនមានការស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត។



Scanned by CamScanner

- ជនជាប់ចោទឈ្មោះ[redacted]ធីតា បានឆ្លើយថា : នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ ខ្លួន និងសង្សាររបស់ខ្លួនឈ្មោះ[redacted]ប៊ុនថន បានកំពុងជក់ថ្នាំញៀននៅក្នុងបន្ទប់ជួលស្រាប់តែសមត្ថកិច្ចបានចូលមកឆែកឆេរនិងចាប់ឃាត់រូបខ្លួន និងសង្សារខ្លួនឈ្មោះ[redacted]ប៊ុនថន នៅពេលនោះតែម្តង។ ថ្នាំនេះ គឺជារបស់ឈ្មោះ[redacted]ប៊ុនថន មិនដឹងគាត់បានមកពីណាទេ ខ្លួនធ្លាប់ឃើញ សង្សាររបស់ខ្លួនឈ្មោះ [redacted]ប៊ុនថន វែកជាកញ្ចប់តូចៗទុកសម្រាប់លក់ ប៉ុន្តែខ្លួនមិនដឹងថាគាត់លក់ឱ្យអ្នកណាទេ ខ្លួនមិនបានសួរដេញដោលគាត់។ ខ្លួនសន្យាឈប់ប្រព្រឹត្តអំពើនេះតទៅទៀតហើយ ខ្លួនមានការស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ខ្លួនមិនដែលលក់ថ្នាំញៀនទេ ។ សំណូមពរសូមតុលាការមេត្តាបន្ធូរបន្ថយទោសឱ្យផង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា : ឆ្លងតាមការសួរដេញដោលនាពេលសវនាការឃើញថាជនជាប់ចោទបានប្រព្រឹត្តដូចការចោទប្រកាន់មែន ហេតុនេះអយ្យការសូមរក្សាបទចោទប្រកាន់ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការផ្តន្ទាទោសដល់ជនជាប់ចោទតាមច្បាប់ ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ប៊ុនថន បានធ្វើសេចក្តីសន្និដ្ឋានថា : កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពកំហុស ដោយមិនមានការលាក់បាំងអ្វីទេ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ ល្ងង់ខ្លៅ ខ្វះការយល់ដឹងពីវិស័យច្បាប់ ព្រមទាំងមានការសោកស្តាយនូវកំហុសរបស់ខ្លួន ដែលបានប្រព្រឹត្ត ព្រមទាំងសន្យាថា និងឈប់ប្រព្រឹត្តអំពើខុសឆ្គងនេះតទៅទៀតហើយ ហេតុនេះសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោស ដោយផ្តល់នូវស្ថានសម្រាលដល់កូនក្តីរបស់ខ្លួនដោយអនុគ្រោះ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ[redacted]ធីតា បានធ្វើសេចក្តីសន្និដ្ឋានថា : កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពកំហុស ដោយមិនមានការលាក់បាំងអ្វីទេ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ ល្ងង់ខ្លៅ ខ្វះការយល់ដឹងពីវិស័យច្បាប់ ព្រមទាំងមានការសោកស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ព្រមទាំងសន្យាថា និងឈប់ប្រព្រឹត្តអំពើខុសឆ្គងនេះតទៅទៀតហើយ ហេតុនេះសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោស ដោយផ្តល់នូវស្ថានសម្រាលដល់កូនក្តីរបស់ខ្លួនដោយអនុគ្រោះ។

-ក្រោយពីបានដំណើរការសួរដេញដោលរួចរាល់ហើយ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានចោទប្រកាន់ និងប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យកំណត់ហេតុ ឯកសារ ភ័ស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការ**

**យល់ឃើញថា :**

-កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ ពិតជាមានអំពើរក្សាទុក ជួញដូរ និងសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយឈ្មោះ[redacted]ប៊ុនថន និងឈ្មោះ[redacted]ធីតា ប្រាកដមែន ។



Scanned by CamScanner

-ចម្លើយរបស់ឈ្មោះ [redacted] ប៊ុនថន និងឈ្មោះ [redacted] ធីតា ព្រមទាំងភស្តុតាងដាក់បន្ទុកនានាគឺមានលក្ខណៈគ្រប់គ្រាន់និងស៊ីសង្វាក់គ្នាដែលអាចកំណត់បានថា កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ ឈ្មោះ [redacted] ប៊ុនថន ពិតជាបានទិញថ្នាំញៀនយកមកវែកជាកញ្ចប់តូចៗ លក់ចែកចាយបន្ត ព្រមទាំងបានរក្សាទុកថ្នាំញៀនមួយកញ្ចប់តូចក្នុងហោប៉ៅ ប្រាកដមែន ដែលអំពើនេះគឺជាបទល្មើស "រក្សាទុក និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤០ កថាខណ្ឌ ១,៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-ឈ្មោះ [redacted] ធីតា ដែលត្រូវជាសង្សារ [redacted] ប៊ុនថន ឃើញឈ្មោះ [redacted] ប៊ុនថន វែកថ្នាំញៀនជាកញ្ចប់តូចៗ ដើម្បីលក់ចែកចាយផងដែរ តែមិនបានរាយការណ៍ដល់សមត្ថកិច្ច ដែលអំពើនេះគឺជាបទល្មើស "សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" នៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ២៩ន នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ កថាខណ្ឌ ៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តំណាងអយ្យការបានធ្វើសន្និដ្ឋានថា: សូមរក្សាបទចោទឱ្យនៅដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់នោះឃើញថាមានលក្ខណៈត្រឹមត្រូវតុលាការគប្បីធ្វើការពិចារណា។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ប៊ុនថន បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពកំហុស ដោយមិនមានការលាក់បាំងអ្វីទេ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ ល្ងង់ខ្លៅ ខ្វះការយល់ដឹងពីវិស័យច្បាប់ មានការសោកស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ព្រមទាំងសន្យាថា នឹងឈប់ប្រព្រឹត្តអំពើខុសឆ្គងនេះតទៅទៀតហើយ ហើយសំណូមពរឱ្យតុលាការមេត្តាបន្ធូរបន្ថយទោស ដោយផ្តល់នូវស្ថានសម្រាលដល់កូនក្តីរបស់ខ្លួនដោយអនុគ្រោះ នោះតុលាការនឹងធ្វើការពិចារណា។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីតា បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីរបស់ខ្លួនបានឆ្លើយសារភាពកំហុស ដោយមិនមានការលាក់បាំងអ្វីទេ កូនក្តីរបស់ខ្លួនមានជីវភាពក្រីក្រ ល្ងង់ខ្លៅ ខ្វះការយល់ដឹងពីវិស័យច្បាប់ មានការសោកស្តាយនូវកំហុសរបស់ខ្លួនដែលបានប្រព្រឹត្ត ព្រមទាំងសន្យាថា និងឈប់ប្រព្រឹត្តអំពើខុសឆ្គងនេះតទៅទៀតហើយថាកូនក្តីខ្លួនគ្មានចេតនា សមគំនិតអ្វីជាមួយឈ្មោះ [redacted] ប៊ុនថន ក្នុងការប្រព្រឹត្តអំពើជួញដូរថ្នាំញៀននោះទេ ក៏ប៉ុន្តែដោយហេតុថាឈ្មោះ [redacted] ប៊ុនថន នេះត្រូវជាសង្សាររបស់នាង ទើបធ្វើឱ្យនាងមិនហ៊ាន សួរនាំ និងរាយការណ៍ប្រាប់សមត្ថកិច្ច ហើយសំណូមពរតុលាការមេត្តាបន្ធូរបន្ថយទោស ដោយផ្តល់នូវស្ថានសម្រាលដល់កូនក្តីរបស់ខ្លួនដោយអនុគ្រោះ នោះឃើញថាមានលក្ខណៈសមហេតុផលដែលតុលាការគប្បីធ្វើការពិចារណា។

-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ប៊ុនថន និងឈ្មោះ [redacted] ធីតា ប្រព្រឹត្តឡើងក្នុងចេតនាទុច្ចរិត ជននេះជាមនុស្សមានស្មារតីល្អមានការយល់ដឹងបានច្បាស់លាស់ពីអំពើ និងបច្ច័យដែលកើតមានឡើងដោយអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត តែជនរូបនេះនៅតែប្រព្រឹត្តបទល្មើសដោយបានធ្វើសកម្មភាព រក្សាទុក ជួញដូរ និងសមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលអំពើនេះធ្វើឱ្យប៉ះពាល់ដល់សុខភាព អាយុជីវិតរបស់មនុស្សជាតិ ធ្វើឱ្យខូចរបៀបរៀបរយសន្តិសុខសណ្តាប់ធ្នាប់សាធារណៈខុសនឹងច្បាប់ព្រហ្មទណ្ឌដែលចូលជាធរមាន។

-មានភស្តុតាងដាក់បន្ទុក.ធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់ស្តើពីឈ្មោះ ប៊ូ ប៊ុនថន ពីបទ



Scanned by CamScanner

" រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបកាលពីថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០១៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី១,៣,៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-មានភ័ស្ដុតាងដាក់បន្ទុក.ធាតុផ្សំបទល្មើស និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោ[redacted]ធីតា ពីបទ " សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាបកាលពីថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០១៦។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤០ កថាខណ្ឌទី ៣,៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

-វត្ថុតាងមាន :

១.ស្រោមសំបុត្រពណ៌សបិទជិតដែលមានផ្ទុកសារធាតុញៀន មានស្នាមមេដៃរបស់ឈ្មោះ [redacted]ប៊ុនថន និងហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ចំនួន ០១

២.ស្រោមសំបុត្រពណ៌ខ្ចីមខ្លុះបិទជិតដែលមានផ្ទុកសារធាតុញៀនមានស្នាមមេដៃរបស់ឈ្មោះ ប៊ូ ប៊ុនថន ចំនួន ០១

៣.ទូរស័ព្ទដៃចំនួន ០៣គ្រឿង(ម៉ាកNokia ពណ៌ក្រហមលាយខ្មៅចំនួន ០១គ្រឿង និងពណ៌ឈាមជ្រូកលាយខ្មៅចំនួន ០១គ្រឿង និងម៉ាក់ Samsung ពណ៌ខ្មៅ ០១គ្រឿង (បែកកញ្ចក់មុខគ្មានសំបកក្រោយ) ដែលជាមធ្យោបាយបម្រើក្នុងការប្រព្រឹត្តបទល្មើសគប្បីសម្រេចរឹបអូស និងបំផ្លាញចោល ។

(វត្ថុតាងទាំងនេះ បច្ចុប្បន្នត្រូវបានរក្សាទុកដោយលោក[redacted]ហាវ៉ា តាមដីកាបង្គាប់ឱ្យរក្សាទុកវត្ថុតាងចាប់យកលេខ: ៣១០ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ២០១៦)

ជនជាប់ចោទឈ្មោះ [redacted]ធីតា បានឆ្លើយថា ខ្លួនធ្លាប់ឃើញ សង្សាររបស់ខ្លួនឈ្មោះ [redacted]ប៊ុនថន វ៉ែលេកថ្នាំជាកញ្ចប់តូចៗ ប៉ុន្តែខ្លួនមិនដឹងថាគាត់លក់ឱ្យអ្នកណាទេ ខ្លួនមិនហ៊ានសួរនាំព្រោះ [redacted] ប៊ុនថន ជាសង្សាររបស់ខ្លួន ហើយសំណូមពរ សុំឱ្យតុលាការមេត្តាសម្រាលទោសឱ្យខ្លួនផងនោះ ។ ឃើញថាមានលក្ខណ:សមហេតុផល ដែលតុលាការគប្បីផ្ដល់នូវស្ថានសម្រាលខ្លះៗដល់ជនជាប់ចោទរូបនេះ តាមមាត្រា ៩៣ និង ៩៤នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះ សម្រេច

### I.ផ្ដន្ទាទោស

១.ឈ្មោះ[redacted]ប៊ុនថន ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ ០៣ ឆ្នាំនិង ០៦ខែ(បីឆ្នាំប្រាំមួយខែ)

-ពីបទ " រក្សាទុក និងជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌ



Scanned by CamScanner

ដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៤០កថាខណ្ឌទី១,៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.ឈ្មោះ [redacted] ភេទស្រី អាយុ ១៨ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារកំណត់ ០១ ឆ្នាំ (មួយឆ្នាំ)

ពីបទ "សមគំនិតក្នុងអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន" ប្រព្រឹត្តនៅភូមិតាភុល សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០១៦ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា២៩ នៃក្រមព្រហ្មទណ្ឌ និងមាត្រា៤០ កថាខណ្ឌទី៣,៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងមាត្រា៩៣ និង៩៤ នៃក្រមព្រហ្មទណ្ឌ ។

**II.វត្ថុតាងមាន**

១.ស្រោមសំបុត្រពណ៌សបិទជិត ដែលមានផ្ទុកសារធាតុញៀន មានស្នាមមេដៃរបស់ឈ្មោះ [redacted] និងហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ចំនួន ០១

២.ស្រោមសំបុត្រពណ៌ខ្ចីមខ្នុរបិទជិតដែលមានផ្ទុកសារធាតុញៀនមានស្នាមមេដៃរបស់ឈ្មោះ [redacted] ចំនួន ០១

៣.ទូរស័ព្ទដៃចំនួន ០៣គ្រឿង(ម៉ាកNokia ពណ៌ក្រហមលាយខ្មៅចំនួន ០១គ្រឿង និងពណ៌ឈាមជ្រូកលាយខ្មៅចំនួន ០១គ្រឿង និងម៉ាក់ Samsung ពណ៌ខ្មៅ ០១គ្រឿង (បែកកញ្ចក់មុខគ្មានសំបកក្រោយ) ត្រូវរឹបអូស និងបំផ្លាញចោល។

សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅសាលាដំបូងខេត្តសៀមរាបចំពោះមុខជនជាប់ចោទ។

ទុកសិទ្ធិឱ្យប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**
ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**
ហត្ថលេខា និងត្រា [redacted]

---

បានឃើញ
ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧
**ចៅក្រមជំនុំជម្រះ**
[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
សៀមរាប,ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០១៧
**ក្រឡាបញ្ជី**
[redacted]

Scanned by CamScanner